# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# ការបោះពុម្ពសន្លឹកឆ្នោតបំរុងសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧

ភ្នំពេញ, ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ បានបង្ហាញនូវការបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ មានចំនួន៩.៤២៦.៦០០សន្លឹក(រាប់ទាំងសន្លឹកឆ្នោតបំរុង) ជាមួយទឹកប្រាក់ចំណាយអស់ចំនួន២លានដុល្លារអាមេរិក ដែលក្នុងនោះមានប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត ត្រឹមតែចំនួន ៧.៨៦៥.០៣៣នាក់។

ការបោះពុម្ពសន្លឹកឆ្នោតនេះលើសដល់ចំនួន១.៥៦១.៥៦៧សន្លឹក ស្មើនឹង១៩.៨៥%នៃអ្នកមានឈ្មោះនៅក្នុងបញ្ជីឈ្មោះដែលគិតជាការប្រើប្រាស់ថវិកាអស់ប្រហែល ៣៣ម៉ឺនដុល្លារអាមេរិក។

អង្គការសង្គមស៊ីវិលនៅកម្ពុជានៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ បានយល់ឃើញថា៖

១. ការបោះពុម្ពនេះបានប្រើប្រាស់ថវិកាខ្ជះខ្ជាយលើសន្លឹកឆ្នោតបំរុងច្រើនពេក

២. ការព្រួយបារម្ភនៃហានិភ័យក្នុងការប្រើប្រាស់សន្លឹកឆ្នោតដែលបំរុងទុកមិនត្រឹមត្រូវ

អង្គការសង្គមស៊ីវិលនៅកម្ពុជានៃបន្ទប់ស្ថានការណ៍ ផ្តល់អនុសាសន៍ថា៖ សន្លឹកឆ្នោតបំរុង គ.ជ.ប គួរតែបោះពុម្ពក្នុងកម្រិតនៃការគ្រប់គ្រងមានហានិភ័យទាបបានហើយ គឺចំនួនលើសត្រឹម ៥% នៃអ្នកមានឈ្មោះនៅក្នុងបញ្ជីឈ្មោះ ជាក់ស្តែងនៅក្នុងប្រទេសខ្លះ ការបោះពុម្ពសន្លឹកឆ្នោតបំរុងនេះ គេធ្វើត្រឹមតែ ២%ប៉ុណ្ណោះ។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**


| | | |
|---|---|---|
| ១. លោកស្រី ធីតា ឃឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ២. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |
| ៣. លោក សំ គន្ធាមី | នាយក និកហ្វិច | ០១២ ៨២២ ២៧៣ |
| ៤. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ៥. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ៦. លោក ស៊ឹង សែនករុណា | មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ ADHOC | ០៨៩ ៦៦៦ ៣១២ |
| ៧. លោក មឿន តុលា | នាយកប្រតិបត្តិសង់ត្រាល | ០៩៣ ៥៥៦ ៦៤៣ |
| ៨. លោក ឡាយ សុវត្ថារ៉ា | ប្រធានកម្មវិធីសិទ្ធិទទួលបានយុត្តិធម៌ និងកម្មវិធីសិទ្ធិការងារ (CLEC) | ០១២ ៨០៣ ៨២៧ |
| ៩. លោក ថេង សាវឿន | អគ្គលេខាធិការសម្ព័ន្ធសហគមន៍កសិករកម្ពុជា | ០៧៨ ២២៥ ០៨៨ |


---

COMFREL, NICFEC, ADHOC, LICADHO, CLEC, SILAKA, YRDP, KYSD, PDP-Center, CCFC, CENTRAL, STT, CCIM, CYN, BPO, GADC, CCC, NGO Forum, HRTF, DPA, KYA, FACT, WMC, YCUD, CIYA, YEDP, CYWEN, IDEA, CFSWF, PBO, NGO CEDAW, CVS, TIC, CGCN, YFP, CPN, ANSA-EAP, CCHR, CLC, CDPO.